

ព័ត៌មានកម្មវិធី SPCR

# ការប្រែប្រួលអាកាសធាតុ

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR)

នាយកដ្ឋានប្រែប្រួលអាកាសធាតុ
ខែកញ្ញា ឆ្នាំ២០១៧ លេខ ១០

## ការធ្វើតេស្តសាកល្បងប្រើប្រាស់ឧបករណ៍បង្រួមមាត្រដ្ឋានព័ត៌មានភូមិសាស្ត្រសម្រាប់ការប្រែប្រួលអាកាសធាតុ

នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពបានបណ្តុះបណ្តាល និងធ្វើតេស្តសាកល្បងប្រើប្រាស់ “ឧបករណ៍បង្រួមមាត្រដ្ឋានព័ត៌មានភូមិសាស្ត្រសម្រាប់ការប្រែប្រួលអាកាសធាតុ” ជាមួយក្រុមការងារជំនាញប្រែប្រួលអាកាសធាតុដែលអញ្ជើញមកពីក្រសួងស្ថាប័នពាក់ព័ន្ធ និងអង្គការមិនមែនរដ្ឋាភិបាល នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៧។




ឯកឧត្តមសាស្ត្រាចារ្យបណ្ឌិត សាបូ អូហ្សាណូ មានប្រសាសន៍នាឱកាសបើកសិក្ខាសាលាបណ្តុះបណ្តាលស្តីពី “ឧបករណ៍បង្រួមមាត្រដ្ឋានព័ត៌មានភូមិសាស្ត្រសម្រាប់ការប្រែប្រួលអាកាសធាតុ”

សិក្ខាសាលាបណ្តុះបណ្តាលនេះត្រូវបានដឹកនាំដោយឯកឧត្តម សាស្ត្រាចារ្យ បណ្ឌិត សាបូ អូហ្សាណូ រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាប្រធានសម្របសម្រួលកម្មវិធីSPCR ជាមួយឯកឧត្តម ជួប ប៉ារីស៍ អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងបណ្ឌិត Ancha Srinivasan អ្នកឯកទេសប្រែប្រួលអាកាសធាតុតំណាងធនាគារអភិវឌ្ឍន៍អាស៊ី ប្រចាំប្រទេសហ្វីលីពីន។ ... តទៅទំព័រទី២

## ទស្សនកិច្ចចុះពិនិត្យ និងតាមដានលទ្ធផលការអនុវត្តគម្រោងភាពធន់នឹងអាកាសធាតុនៅតាមសហគមន៍

កាលពីថ្ងៃទី១២ដល់ទី១៤ខែកក្កដាឆ្នាំ២០១៧ កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR) ដឹកនាំដោយឯកឧត្តម សាស្ត្រាចារ្យ បណ្ឌិត សាបូ អូហ្សាណូ រដ្ឋលេខាធិការ ក្រសួងបរិស្ថាន និងជាប្រធានសម្របសម្រួលកម្មវិធី SPCR បានចុះពិនិត្យ និងតាមដានលទ្ធផលការអនុវត្តគម្រោងគាំទ្រភាពធន់នឹងអាកាសធាតុនៅតាមសហគមន៍ដែលអនុវត្តដោយអង្គការសង្គមស៊ីវិលដែលទទួលបានកញ្ចប់ថវិកាពីមូលនិធិវិនិយោគអាកាសធាតុ តាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី ក្រសួងបរិស្ថាន និងអង្គការ ផ្លែន អន្តរជាតិ ដែលជាស្ថាប័នសម្របសម្រួលកម្មវិធី SPCR។ ... តទៅទំព័រទី២



### មាតិកា

កិច្ចប្រជុំលើកទី៦របស់ក្រុមការងារសម្របសម្រួលកម្មវិធី .........ទំព័រ ៣
បង្កើនការគ្រប់គ្រងធនធានទឹកដែលធន់នឹងអាកាសធាតុ..........ទំព័រ ៣
លើកកម្ពស់ភាពធន់ទៅនឹងអាកាសធាតុ..............................ទំព័រ ៤
ការបញ្ជ្រាបយេនឌ័រទៅក្នុងផែនការបន្សាំ..............................ទំព័រ ៥
សកម្មភាពបន្ទាប់...........................................................ទំព័រ ៦

## ការធ្វើតេស្តសាកល្បង...

នៅក្នុងពិធីបើកសិក្ខាសាលាបណ្តុះបណ្តាលនេះ ឯកឧត្តម សាស្ត្រាចារ្យ បណ្ឌិត សាបូ អូហ្សាណូបានមានប្រសាសន៍ថា “ឧបករណ៍នេះនឹងជួយដល់អ្នកពាក់ព័ន្ធនូវការប្រើប្រាស់ព័ត៌មានភូមិសាស្ត្រ និងវិធីសាស្ត្របង្រួមមាត្រដ្ឋានដូចៗគ្នាឱ្យបានសមស្របបំផុត។ ជាមួយគ្នានេះ ឯកឧត្តមបានបញ្ជាក់បន្ថែមថា យើងក៏មានភាពប្រឈមក្នុងការប្រមូលនិងវិភាគទិន្នន័យតាមបែបវិទ្យាសាស្ត្រ និងទាមទារឱ្យមានបច្ចេកវិទ្យាទំនើបៗដើម្បីព្យាករពីនិន្នាការនៃការប្រែប្រួលអាកាសធាតុ”។


ការធ្វើលំហាត់ជាក្រុម "ប្រើប្រាស់ឧបករណ៍ប្រព័ន្ធព័ត៌មានភូមិសាស្ត្រអាកាសធាតុសម្រាប់ករណីសិក្សាជាក់លាក់"

គោលបំណងនៃការជួបជាមួយក្រុមការងារជំនាញប្រែប្រួលអាកាសធាតុទាំងនេះ គឺដើម្បីបង្ហាញឧបករណ៍គាំទ្រសេចក្តីសម្រេចចិត្តដោយផ្អែកលើប្រព័ន្ធ ព័ត៌មានភូមិសាស្ត្រជាថ្មីម្តងទៀតបន្ទាប់ពីត្រូវបានធ្វើបច្ចុប្បន្នភាពដោយបានដាក់បញ្ចូលព័ត៌មានទិន្នន័យតាមបែបវិទ្យាសាស្ត្របន្ថែម ទាក់ទងនឹងអាកាសធាតុដែលត្រូវបានព្យាកររហូតដល់ឆ្នាំ២០៥០នៅគ្រប់ខេត្តក្រុងនៅប្រទេសកម្ពុជា ជាភាសាខ្មែរ និងអង់គ្លេស និងប្រមូលមតិយោបល់បន្ថែមទៀតដើម្បីកែលម្អឧបករណ៍នេះសម្រាប់រៀបចំសៀវភៅណែនាំដល់អ្នកប្រើប្រាស់។

បណ្ឌិត Srinivasan ក៏បានឱ្យដឹងថា ឧបករណ៍នេះនឹងត្រូវធ្វើតេស្តសាកល្បងប្រើប្រាស់ដោយមន្ត្រីជំនាញតាមវិស័យពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដើម្បីគ្រប់គ្រង និងធ្វើបច្ចុប្បន្នភាពទិន្នន័យ មុននឹងដាក់បង្ហោះលើប្រព័ន្ធអ៊ីនធឺណែត សម្រាប់សាធារណជន ជាពិសេសអ្នករៀបចំផែនការ អ្នកធ្វើគោលនយោបាយ និងអ្នកធ្វើសេចក្តីសម្រេចចិត្តអាចទាញយកទិន្នន័យទាំងនេះមកប្រើប្រាស់។


ការធ្វើលំហាត់ជាក្រុម "ប្រើប្រាស់ឧបករណ៍ប្រព័ន្ធព័ត៌មានភូមិសាស្ត្រអាកាសធាតុសម្រាប់ករណីសិក្សាជាក់លាក់"

## ទស្សនកិច្ចចុះពិនិត្យ ...

នៅខេត្តស្ទឹងត្រែង ក្រុមការងារបានចុះពិនិត្យមើល៖

- ស្ថានីយ៍ប្រព័ន្ធទឹកស្អាត នៅភូមិត្បូងខ្លា
- ជួបពិភាក្សាការងារជាមួយមេឃុំ អាជ្ញាធរនិងប្រធានសហគមន៍អេកូទេសចរណ៍ធម្មជាតិពីដំណើរការអភិវឌ្ឍន៍នៅឃុំកោះព្រះ។



នៅខេត្តរតនគិរីក្រុមការងារបានចុះពិនិត្យមើល៖

- ការថ្នាលបណ្តុះគ្រាប់ពូជបន្លែ ធុងចំរោះទឹកស្អាត ធុងស្តុកទឹកភ្លៀង សំភារៈសម្រាប់ទីទួលសុវត្ថិភាព ការចិញ្ចឹមមាន់ និងបង្គោលវាស់កម្ពស់ទឹកឡើងនៅរដូវវស្សានៅភូមិកាលឹម ភូមិទាមលើ(ស្រុកវើនសៃ) និងភូមិកាជូតក្រោម ភូមិដាល (ស្រុកអណ្តូងមាស)

នៅខេត្តមណ្ឌលគិរីក្រុមការងារបានចុះពិនិត្យមើល៖

- ប្រព័ន្ធបូមទឹកដោយប្រើថាមពលព្រះអាទិត្យ និងសំណេះសំណាលជាមួយសហគមន៍ពីការអភិវឌ្ឍក្រោមការជួយគាំទ្ររបស់គម្រោង និងសំណូមពរផ្សេងៗនៅភូមិបរគូង ឃុំពូជ្រៃ ស្រុកពេជ្រាដា







## កិច្ចប្រជុំលើកទី៦របស់ក្រុមការងារសម្របសម្រួលកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ

នាយកដ្ឋានប្រែប្រួលអាកាសធាតុនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាពបានសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដែលអនុវត្តគម្រោងវិនិយោគក្រោមកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ(SPCR) និងគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស(TA) បានជួបជុំគ្នានៅព្រឹកថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១៧នេះ នៅរាជធានីភ្នំពេញ។




កិច្ចប្រជុំនេះ ដឹកនាំដោយឯកឧត្តម សាស្ត្រាចារ្យ បណ្ឌិត សាបូ អូហ្សាណូ រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាប្រធានក្រុមការងារសម្របសម្រួលកម្មវិធី ឯកឧត្តមជួប ប៉ារីស៍ អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព និងបណ្ឌិត តូច ច័ន្ទក្រឹស្នា អគ្គនាយករងនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បី(១) ចែករំលែកពីវឌ្ឍនភាព សមិទ្ធផល និងបញ្ហាប្រឈមផ្សេងៗរបស់គម្រោងវិនិយោគនីមួយៗក្នុងរយៈពេល ៦ ខែចុងក្រោយនេះ ចាប់ពីខែមករា ដល់មិថុនា ឆ្នាំ២០១៧។ (២)បទបង្ហាញពីមគ្គុទេសក៏បន្សុំាតាមវិស័យដែលបានរៀបចំដោយគម្រោងTA និងកំណត់ចំណុចចាប់ផ្តើមនៃការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការ។ (៣) បទបង្ហាញពីវឌ្ឍនភាព និងបទពិសោធបញ្ជ្រាបការប្រែប្រួលអាកាសធាតុទៅក្នុងគម្រោងវិនិយោគអាកាសធាតុ និងផែនការយុទ្ធសាស្ត្រ ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុរបស់ក្រសួងនីមួយៗដែលអនុវត្តគម្រោងវិនិយោគ។(៤) ពិភាក្សាជាក្រុមតាមវិស័យ ដើម្បីកំណត់ចំណុចចាប់ផ្តើមការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ។(៥) បទបង្ហាញ និងកិច្ចពិភាក្សាវឌ្ឍនភាពការសិក្សាលម្អិត ពីលទ្ធភាពគម្រោងបន្សុំាទាំង៦សម្រាប់ការសរសេរសំណើគម្រោងស្វែងរកមូលនិធិពីសហគមន៍អន្តរជាតិ និង(៦) ពិភាក្សាលើវឌ្ឍនភាព និងឱកាសសម្រាប់សហប្រតិបត្តិការ និងការរៀនសូត្រពីគ្នាក្នុងចំណោមគម្រោងក្រោមកម្មវិធី SPCR។

ឯកឧត្តមប្រធានដឹកនាំកិច្ចប្រជុំនេះ ក៏បានស្នើគម្រោងវិនិយោគទាំងអស់ សូមមេត្តាពន្លឿនសកម្មភាព ដែលកំពុងអនុវត្តដោយក្រសួងស្ថាប័នពាក់ព័ន្ធ ដើម្បីបញ្ចប់រាល់លទ្ធផលដែលរំពឹងទុកតាមផែនការ ដោយសារគម្រោងមួយចំនួននឹងត្រូវបញ្ចប់នៅប៉ុន្មានឆ្នាំខាងមុខនេះ ជាពិសេសគម្រោងដែលត្រូវបញ្ចប់ក្នុងឆ្នាំ២០១៨ និង២០១៩។






## បង្កើនការគ្រប់គ្រងធនធានទឹកដែលធន់នឹងអាកាសធាតុក្នុងខេត្តពោធិ៍សាត់ និងបាត់ដំបង

រាជរដ្ឋាភិបាលកម្ពុជា តាមរយៈក្រសួងធនធានទឹក និងឧតុនិយម កំពុងវិនិយោគក្នុងការបង្កើនភាពធន់នឹងអាកាសធាតុ និងការកាត់បន្ថយហានិភ័យទឹកជំនន់ ដោយស្តារឡើងវិញប្រឡាយស្រោចស្រពដំណាក់ឈើក្រម និងប្រព័ន្ធបង្ហូរទឹក។ ប្រព័ន្ធប្រឡាយនេះ គឺមានទីតាំងនៅជួរជើងភ្នំក្រវាញក្នុងខេត្តពោធិ៍សាត់ និងបាត់ដំបង។ តំបន់នេះងាយរងគ្រោះទឹកជំនន់គំហុកដែលហូរចុះពីភ្នំ ហើយក៏មានភាពរាំងស្ងួតរយៈពេលយូរកាលពីជាង១០ឆ្នាំមុន ជាមួយប្រព័ន្ធស្រោចស្រព និងបង្ហូរទឹកដែលមានសភាខូចខាត នាំឱ្យកាន់តែមានភាពប្រឈមនឹងហានិភ័យទាំងនេះ។

មុនការសាងសង់ចាប់ផ្តើម អ្នកជំនាញបច្ចេកទេសមកពីគម្រោងបង្កើនការគ្រប់គ្រងទឹកជំនន់ និងភាពរាំងស្ងួតក្នុងខេត្តពោធិ៍សាត់ កំពុងធ្វើការជាមួយក្រសួងធនធានទឹក និងឧតុនិយមដើម្បីបង្កើតម៉ូដែលព្យាករផលប៉ះពាល់ ពីការប្រែប្រួលអាកាសធាតុលើធនធានទឹកក្នុងប្រព័ន្ធប្រឡាយ។ ព័ត៌មាននេះ



នឹងជួយដល់វិស្វករ ដើម្បីរៀបចំបទដ្ឋានសម្រាប់ការងារស្តារប្រឡាយឡើងវិញនៅដំណាក់កាលទី១ ដែលនឹងកាត់បន្ថយហានិភ័យភាពរាំងស្ងួត និងទឹកជំនន់ក្នុងខេត្តពោធិ៍សាត់ ស្របតាមសេណារីយ៉ូអាកាសធាតុនាពេលអនាគត។ គម្រោងនេះ គាំទ្រថវិកាដោយមូលនិធិវិនិយោគអាកាសធាតុតាមរយៈធនាគារអភិវឌ្ឍន៍អាស៊ីក្រោមកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ។

... តទៅទំព័រទី៤

### បង្កើនការគ្រប់គ្រងធនធានទឹក ...

ជាមួយគ្នានេះដែរ គម្រោងបានបណ្តុះបណ្តាលប្រជាពលរដ្ឋចំនួន៤៦ភូមិ ដែលរស់នៅជុំវិញប្រឡាយដំណាក់ឈើក្រម ដើម្បីបង្កើត និងអនុវត្តផែនការភូមិឃុំមានសុវត្ថិភាព។ ផែនការភូមិឃុំមានសុវត្ថិភាព ពិពណ៌នាពីជំហានដែលសហគមន៍ត្រូវអនុវត្តដើម្បីកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ រួមមានប្រព័ន្ធព័ត៌មានប្រកាសអាសន្ន ដែលគ្រប់គ្រងកម្ពស់ទឹកក្នុងប្រឡាយ និងប្រកាសដល់អ្នកភូមិនៅពេលចាំបាច់ត្រូវជម្លៀស។

គម្រោងហិរញ្ញប្បទាន សហប្រតិបត្តិការបច្ចេកទេស ការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ ទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍នៃកម្មវិធីSPCR ក៏កំពុងជួយគាំទ្រការវិភាគបច្ចេកទេសដល់ក្រសួងធនធានទឹកនិងឧតុនិយមផងដែរ។គម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ ទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ ( MCRDP )កំពុងសិក្សាលម្អិតពីលទ្ធភាពគម្រោងបន្សាំ ក្នុងការពង្រីកប្រព័ន្ធប្រឡាយដំណាក់ឈើក្រម និងប្រព័ន្ធស្រោចស្រពដោយស្តារឡើងវិញ និងភ្ជាប់ប្រឡាយខេត្តបាត់ដំបង និងពោធិ៍សាត់។ គម្រោង MCRDP ក៏កំពុងកំណត់វិធានការផ្លូវជនបទធន់នឹងអាកាសធាតុ ដើម្បីធ្វើឱ្យប្រសើរឡើងផលិតកម្មកសិកម្ម ធន់នឹងអាកាសធាតុ និងទីផ្សារ និងកសាងសហគមន៍ធន់នឹងអាកាសធាតុ។ នៅពេលការសិក្សានេះត្រូវបានបញ្ចប់ គម្រោងMCRDP នឹងជួយក្រសួងធនធានទឹក និងឧតុនិយមដើម្បីស្វែងរកមូលនិធិបន្សាំនឹងការប្រែប្រួលអាកាសធាតុ ដើម្បីធ្វើឱ្យប្រសើរឡើងការគ្រប់គ្រងធនធានទឹក និងកាត់បន្ថយហានិភ័យគ្រោះមហន្តរាយក្លាយជាការពិតសម្រាប់សហគមន៍ជាច្រើន ដែលរស់នៅជុំវិញប្រព័ន្ធប្រឡាយដំណាក់ឈើក្រម។



## លើកកម្ពស់ភាពធន់ទៅនឹងអាកាសធាតុក្នុងចំណោមកសិកររស់នៅតាមដងទន្លេមេគង្គ

នៅក្នុងខេត្តស្ទឹងត្រែង ដែលជាខេត្តគោលដៅរបស់អង្គការផ្លែន អន្តរជាតិ ដំណាំស្រូវ និងដំណាំកសិកម្មប្រមាណ៨០% របស់កសិករ ត្រូវបានរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយសារទឹកជំនន់ហូរមកពីទន្លេមេគង្គ ដែលអូសបន្លាយរយៈពេលយូរ។

ដំណាំ និងផលិតកម្មស្រូវស្ទើរតែទាំងអស់ ត្រូវបានរងការខូចខាតដោយសារតែទឹកជំនន់។ ភ្លៀងធ្លាក់មិនទៀងទាត់បានពន្យាពេលវដ្តផលិតកម្មដំណាំស្រូវ ហើយក៏បានបំផ្លាញផលដំណាំដែលធ្វើឱ្យកសិករជាច្រើន ប្រឈមនឹងហានិភ័យវិបត្តិហិរញ្ញវត្ថុ។

ក្នុងការឆ្លើយតបនឹងបញ្ហាប្រឈមទាំងនោះ ក្រុមការងារអភិវឌ្ឍន៍ជនបទកម្ពុជា (CRDT) បានសាងសង់ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតជាលក្ខណៈគ្រួសារនៅភូមិអូរម្រេះ ខេត្តស្ទឹងត្រែង ដែលសកម្មភាពនេះ ស្ថិតនៅក្រោមជំនួយឥតសំណងពីមូលនិធិវិនិយោគអាកាសធាតុ តាមរយៈធនាគារអភិវឌ្ឍន៍អាស៊ី ក្រោមកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុដោយមានការគ្រប់គ្រងយន្តការគាំទ្រសង្គមស៊ីវិលដោយអង្គការផ្លែន អន្តរជាតិកម្ពុជា។ ប្រជាជនបានបូមទឹកពីទន្លេនៅក្បែរសំណង់អាង ប្រព័ន្ធទឹកដែលទើបសាងសង់ថ្មីនេះ ដើម្បីចែកចាយទៅក្នុងបណ្តាញប្រពន្ធ័បង្ហូរទឹកថ្មី។

រហូតមកដល់ពេលនេះមានប្រជាជនចំនួន ៤៥គ្រួសារ បានធ្វើការតភ្ជាប់បណ្តាញប្រព័ន្ធទឹកនេះ។ ប្រព័ន្ធទឹកនេះអាចផ្គត់ផ្គង់ដល់ប្រជាជនចំនួន ១៥០គ្រួសារ ដើម្បីបំពេញតាមតម្រូវការក្នុងគ្រួសារ និងការងារដាំដុះបន្លែនៅក្បែរផ្ទះរបស់ពួកគាត់។ គម្រោងនេះក៏បានផ្តល់នូវការពង្រឹងសមត្ថភាពទៅដល់សហគមន៍លើបច្ចេកទេសកសិកម្មអាកាសធាតុវៃឆ្លាត (ការចិញ្ចឹមសត្វជាប្រចាំ) និងជួយលើកកម្ពស់សន្តិសុខសេដ្ឋកិច្ចគ្រួសារតាមរយៈការធ្វើឱ្យប្រសើរឡើងនូវការទទួលបានប្រាក់ចំណូល និងលើកកម្ពស់សកម្មភាពអេកូទេសចរណ៍ធម្មជាតិ។

ជាលទ្ធផលកសិករខ្នាតតូចបានធ្វើឱ្យមានការកើនឡើងនូវប្រាក់ចំណូលរបស់ប្រជាពលរដ្ឋ និងជួយលើកកម្ពស់របបម្ហូបអាហារប្រចាំថ្ងៃ និងបរិមាណទឹកប្រចាំឆ្នាំដែលធ្វើឱ្យមានលទ្ធផលជាវិជ្ជមានក្នុងការឆ្លើយតបទៅនឹងតម្រូវការសុខភាព និងការអប់រំរបស់កុមារ។



“ខ្ញុំបានចូលរួមជាមួយសកម្មភាពផ្សេងៗ របស់គម្រោងចាប់តាំងពីខែសីហាឆ្នាំ២០១៦មកម្ល៉េះ។ ខ្ញុំបានចូលរួមក្នុងសកម្មភាពរបស់គម្រោងដូចជាកិច្ចប្រជុំសន្សំប្រាក់ប្រចាំខែ ការ

... តទៅទំព័រទី៥

## លើកកម្ពស់ភាពធន់ទៅនឹងអាកាសធាតុ ...

ចូលរួមវគ្គបណ្តុះបណ្តាលរួមជាមួយការអនុវត្តជាក់ស្តែងស្តីពីការដាំបន្លែ បច្ចេកទេសដំណាំស្រូវ និងការចិញ្ចឹមមាន់។ ខ្ញុំពិតជាមានមោទនភាព និងរីករាយខ្លាំងណាស់ជាមួយនឹងជំនាញចិញ្ចឹមមាន់ខ្ញុំរៀនបានច្រើនតាមរយៈគម្រោងនេះព្រោះវាជួយគ្រួសារខ្ញុំ និងប្រជានជនដទៃទៀតនៅក្នុងសហគមន៍របស់ខ្ញុំ ទទួលបានប្រាក់ចំណូលច្រើន ហើយនៅពេលយើងអនុវត្តតាមបច្ចេកទេសដែលយើងបានរៀន យើងកាន់តែមានភាពងាយស្រួលក្នុងការទទួលបានអាហារសម្រាប់បរិភោគ»។ សម្តីរបស់អ្នកស្រី ផិត គន្ធី អាយុ ៥៥ ឆ្នាំ ស្ត្រីមេម៉ាយនៅភូមិអូរម្រេះ។

"កាលពីមុន មាន់ដែលខ្ញុំចិញ្ចឹមស្ទើរទាំងអស់ត្រូវបានងាប់ដោយសារតែខ្ញុំចិញ្ចឹមតាមបច្ចេកទេសបែបប្រពៃណី/បុរាណ ដោយសារតែខ្ញុំចិញ្ចឹមមាន់ដោយមិនបានដាក់ទ្រុង (ដើរពាសវាលពាសកាល)។ ខ្ញុំមានចំណេះដឹងតិចតួចបំផុតពីការកំណត់រោគសញ្ញានៃជំងឺ និង មូលហេតុនៃជំងឺ ដែលបណ្តាលអោយមាន់ខ្ញុំងាប់។ ខ្ញុំមិនដឹងពីរបៀបថែទាំ និងព្យាបាលសត្វមាន់នោះទេ ហើយក៏មិនបានចាក់ថ្នាំបង្ការជំងឺអ្វីទាំងអស់។ ដូច្នេះខ្ញុំអាចចិញ្ចឹមមាន់សម្រាប់តែហូបប៉ុណ្ណោះ ហើយខ្ញុំអាចលក់មាន់បានតែ ៤-៥ ក្បាលប៉ុណ្ណោះក្នុងមួយឆ្នាំ»។

"ចាប់ពីខែមករាដល់ខែកក្កដាឆ្នាំ២០១៧ ខ្ញុំបានលក់មាន់ ៦០ ក្បាល ហើយទទួលបានប្រាក់ចំណូល ៣០០ ដុល្លារសហរដ្ឋអាមេរិក) ៣,៧៥ដុល្លារសហរដ្ឋអាមេរិក ក្នុងមួយគីឡូក្រាម) ហើយខ្ញុំនៅមានមាន់បន្ទាប់ពីចំនួន៥០ក្បាលទៀត ក្នុងកសិដ្ឋានរបស់ខ្ញុំ។ លើសពីនេះទៀតគ្រួសារខ្ញុំ ហូបមាន់ពីរទៅបីក្បាលក្នុងមួយខែ។ នៅពេលអនាគតខ្ញុំមានគម្រោងពង្រីកការចិញ្ចឹមមាន់នៅក្នុងកសិដ្ឋានរបស់ខ្ញុំ ហើយខ្ញុំនឹងអាចលក់មាន់បានកាន់តែច្រើន។ អរគុណបច្ចេកទេសចិញ្ចឹមមាន់ដែលបានធ្វើឱ្យប្រសើរជាងមុន។

អ្នកស្រីគន្ធីបាននិយាយបន្ថែមទៀតថា អ្នកស្រីសង្ឃឹមថា CRDT និង Plan International នឹងបន្តគាំទ្រភូមិរបស់អ្នកស្រីបន្តទៀតជាពិសេសគាំទ្រទៅដល់កសិករដទៃទៀតដែលមិនបានចូលរួមក្នុងគម្រោងនេះ។



## ការបញ្ជ្រាបយេនឌ័រទៅក្នុងផែនការបន្សុំានឹងការប្រែប្រួលអាកាសធាតុ

ការបញ្ជ្រាបយេនឌ័រ ទៅក្នុងផែនការបន្សុំានឹងការប្រែប្រួលអាកាសធាតុគឺជាសមាសធាតុដ៏សំខាន់នៃការកសាងសង្គមឱ្យកាន់តែមានភាពធន់នឹងអាកាសធាតុ។ ស្ត្រីគឺងាយរងគ្រោះនឹងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុណាស់។ ស្ត្រី និងបុរសមានតួនាទីផ្សេងៗក្នុងសង្គម ការងារក្នុងផលិតកម្មនិងផ្ទះសម្បែងជាដើម។ ហេតុដូច្នេះស្ត្រី និងបុរសក៏នឹងទទួលបានបទពិសោធន៍ផលប៉ះពាល់ ពីការប្រែប្រួលអាកាសធាតុផ្សេងគ្នាផងដែរ។ ជាឧទាហរណ៍ ភាពងាយរងគ្រោះខ្លាំងរបស់ប្រទេសកម្ពុជាទៅនឹងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុ គឺពាក់ព័ន្ធនឹងភាពពឹងផ្អែកសេដ្ឋកិច្ចទៅលើកសិកម្ម ដែលជាវិស័យត្រូវការកម្លាំងពលកម្មច្រើនជាង២ភាគ៣នៃចំនួនស្ត្រី។ ជាក់ស្តែងស្ត្រីកម្ពុជាបានរងឥទ្ធិពលពីគ្រោះធម្មជាតិផ្សេងៗ ដោយសារស្ត្រីទំនងនៅផ្ទះស្ថិតក្នុងតំបន់ដែលងាយរងទឹកជំនន់នៅ ពេលដែលមានគ្រោះមហន្តរាយកើតឡើង ដោយសារបុរសបានផ្លាស់ទៅនៅក្រុងដើម្បីធ្វើការងារ។ ក្នុងនាមជាអ្នកទទួលខុសត្រូវចំពោះកូនៗ និងមនុស្សចាស់ជរា ស្ត្រីប្រឈមនឹងហានិភ័យខ្លាំងអំឡុងពេលគ្រោះមហន្តរាយ។ ថ្វីត្បិតតែស្ត្រីជាអ្នករស់នៅភាគច្រើននៅតំបន់ជនបទ នៅពេលដែលគ្រោះមហន្តរាយកើតឡើង មានស្ត្រីភាគតិចប៉ុណ្ណោះដែលទទួលបានការបណ្តុះបណ្តាល និងចូលរួមវេទិកា




ផ្សេងៗដើម្បីត្រៀមបង្ការគ្រោះមហន្តរាយ និងប្រព័ន្ធឆ្លើយតបដោយសារភាពជាតំណាងស្ត្រីក្នុងការគ្រប់គ្រង និងភាពជាអ្នកដឹកនាំនៅមានកម្រិត។

ដើម្បីធានាប្រសិទ្ធភាពការបញ្ជ្រាបយេនឌ័រនិងពិចារណាទិដ្ឋភាពសង្គមផ្សេងៗ នៃការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេសនៃគម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការ អភិវឌ្ឍន៍បានសិក្សាវាយតម្លៃយេនឌ័រ និងសេដ្ឋកិច្ចសង្គមដែលជាផ្នែកមួយនៃការសិក្សាលម្អិតលទ្ធភាពកសាងសំណើគម្រោងបន្សុំា ក្នុងការអភិវឌ្ឍកសិកម្ម ការគ្រប់គ្រងធនធានទឹក និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

... តទៅទំព័រទី៦

និងក្រុងដើម្បីស្នើទៅមូលនិធិបន្សាំនានា។ លទ្ធផលនៃការសិក្សាវាយតម្លៃយេនឌ័រនេះ ត្រូវបានចែករំលែកក្នុងសិក្ខាសាលាពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការមិនមែនរដ្ឋាភិបាលកាលពីថ្ងៃទី២៩ខែកញ្ញាឆ្នាំ២០១៧នៅរាជធានីភ្នំពេញ។ គោលបំណងនៃសិក្ខាសាលាពិគ្រោះយោបល់នេះរួមមាន៖

- បង្ហាញ និងពិភាក្សាពីលទ្ធផលបឋមនៃការសិក្សាវាយតម្លៃយេនឌ័រ ស្ថានភាពក្រីក្រ និងសេដ្ឋកិច្ចសង្គម ចំពោះគម្រោងបន្សាំទាំង៦
- ប្រមូលមតិយោបល់ និងអនុសាសន៍ល្អៗពីអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីដាក់បញ្ចូលទៅក្នុងរបាយការណ៍នៃការសិក្សាលម្អិតលទ្ធភាពគម្រោងបន្សាំ
- ធ្វើបច្ចុប្បន្នភាពពីជំហានបន្តបន្ទាប់ក្នុងការរៀបចំកសាងសំណើគម្រោងបន្សាំទាំង៦

ឯកឧត្តម សាស្ត្រាចារ្យ បណ្ឌិត សាបូ អូហ្សាណូ រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាប្រធានសម្របសម្រួលកម្មវិធី SPCR មានប្រសាសន៍ថា “យើងបានពិភាក្សាយ៉ាងម៉ត់ចត់ដើម្បីធ្វើឱ្យប្រសើរឡើងនូវការដាក់បញ្ចូលយេនឌ័រ និងសង្គមទៅក្នុងគម្រោងដើម្បីបង្កើនហេដ្ឋារចនាសម្ព័ន្ធធន់នឹងអាកាសធាតុ។ យើងនឹងចែករំលែកអនុសាសន៍ដែលប្រមូលបានទាំងនេះជាមួយក្រសួងពាក់ព័ន្ធ និងពិចារណាវិធានការសម្រាប់ការបញ្ជ្រាបយេនឌ័រទៅក្នុងសកម្មភាពនានា ដែលនឹងជួយធ្វើឱ្យប្រសើរឡើងឯកសារសំណើគម្រោងបន្សាំ ដែលយើងនឹងផ្ញើទៅកាន់មូលនិធិអន្តរជាតិនានា។” ឯកឧត្តមមានប្រសាសន៍បន្ថែមថា “យើងបន្តផ្សព្វផ្សាយលើកកម្ពស់វិធីសាស្ត្រដែលមានប្រសិទ្ធភាពសម្រាប់ការរៀបចំផែនការបន្សាំ ហើយសិក្ខាសាលាពិគ្រោះយោបល់នេះ បាននាំមកនូវការអនុវត្តល្អៗបន្ថែមទៀតដើម្បីអាចប្រើប្រាស់នៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធធន់នឹងអាកាសធាតុនៅប្រទេសកម្ពុជា។



## សកម្មភាពបន្ទាប់

| | |
|---|---|
| ២-៨ តុលា | ការចុះទស្សនកិច្ចផ្លាស់ប្តូរចំណេះដឹងរបស់គណៈប្រតិភូនៃក្រសួងផែនការអភិវឌ្ឍន៍ជាតិរបស់ប្រទេសហ្សាំប៊ី ( Zambia ) នៅប្រទេសកម្ពុជា |
| ៣-៤ តុលា | សន្និសីទថ្នាក់តំបន់ស្តីពីការគ្រប់គ្រងហានិភ័យគ្រោះមហន្តរាយនៅថ្នាក់សហគមន៍ និងការបន្សាំ |
| ២០ តុលា | សិក្ខាសាលាពិគ្រោះយោបល់ស្តីពីការសិក្សាលម្អិតពីលទ្ធភាពគម្រោងបន្សាំ |
| ២០ វិច្ឆិកា | កិច្ចប្រជុំតុមូលជាមួយក្រសួងដែលអនុវត្តកម្មវិធីSPCR សម្រាប់ការវាយតម្លៃពាក់កណ្តាលអណត្តិ |
| ១២ ធ្នូ | កិច្ចប្រជុំលើកទី៧របស់ក្រុមការងារសម្របសម្រួលកម្មវិធីSPCR និងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការមគ្គុទេសក៍បន្សាំ និងករណីសិក្សាស្តីពីភាពធន់នឹងអាកាសធាតុ |
| ១៤-១៥ ធ្នូ | ត្រួតពិនិត្យការអនុវត្តគម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ពាក់កណ្តាលអណត្តិ |

ព័ត៌មានបន្ថែម៖
ឯកឧត្តម សាស្ត្រាចារ្យ បណ្ឌិត សាបូ អូហ្សាណូ រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាប្រធានសម្របសម្រួលកម្មវិធី
លោក មាស សុផល នាយកដឹកនាំកម្មវិធី
លោក អ៊ូ ច័ន្ទជារិទ្ធ ប្រធានគ្រប់គ្រងកម្មវិធី
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
នាយកដ្ឋានប្រែប្រួលអាកាសធាតុ
អគារមរតកតេជោ ឡូត៍លេខ៥០៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ៖ ៨៥៥ ២៣ ៥៣១៤ ៧៧៧
អ៊ីម៉ែល៖ adbspcrta8179@gmail.com
គេហទំព័រ៖ http://www.spcrcambodia.org/kh/